ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងចូលរួមលើកកម្ពស់សុខុមាលភាពមាតា និងទារក ព្រមទាំងរួមចំណែកដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារ ក្នុងគ្រួសារក្រីក្រ ចាប់តាំងពីកូនក្នុងផ្ទៃរហូតដល់អាយុ ២ឆ្នាំ ដើម្បីជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីវិធាន យន្តការគ្រប់គ្រង និងការផ្តល់របបគោលនយោបាយនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារក្រីក្រ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារដែលមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ វិសាលភាពអនុវត្តនេះ អាចត្រូវបានពង្រីកទៅកាន់ក្រុមគោលដៅណាមួយផ្សេងទៀត អាស្រ័យតាមភាពទ្រទ្រង់បាននៃថវិកាជាតិ និងស្ថានភាពសេដ្ឋកិច្ច-សង្គម។

**មាត្រា៤.-**

វាក្យស័ព្ទបច្ចេកទេស ដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យ ដូចខាងក្រោម ៖

- ប័ណ្ណសមធម៌ សំដៅដល់ប័ណ្ណដែលចេញដោយក្រសួងផែនការ តាមរយៈការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ តាមជុំប្រមូលទិន្នន័យ ឬតាមការស្នើសុំ។
- ប័ណ្ណអាទិភាព សំដៅដល់ប័ណ្ណដែលចេញដោយមន្ទីរពេទ្យ សម្រាប់ទទួលសេវាសុខភាពសាធារណៈ និងប័ណ្ណដែលចេញដោយមណ្ឌលសុខភាព សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ។
- មូលដ្ឋានសុខាភិបាលសាធារណៈ សំដៅដល់មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក និងមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ។

## ជំពូកទី២

## របបគោលនយោបាយ និងលក្ខខណ្ឌនៃការទទួលផល

**មាត្រា៥.-**

ប្រាក់ឧបត្ថម្ភ ត្រូវផ្តល់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារក្រីក្រ ដែលមកទទួលសេវាពិនិត្យសុខភាពនៅមូលដ្ឋានសុខាភិបាលសាធារណៈ ជាដំណាក់កាល ដូចខាងក្រោម ៖

ដំណាក់កាលទី១ ៖ ផ្តល់ការឧបត្ថម្ភចំនួន ៤០ ០០០ រៀលក្នុង ១ដង សម្រាប់ការមកទទួលសេវាពិនិត្យផ្ទៃពោះដែលផ្តល់ជាអតិបរមាចំនួន ៤ដង មុនពេលសម្រាលកូន

ដំណាក់កាលទី២ ÷ ផ្តល់ការឧបត្ថម្ភចំនួន ២០០ ០០០ រៀល តែ ១ដងគត់ នៅពេលសម្រាលកូន

ដំណាក់កាលទី៣ ÷ ផ្តល់ការឧបត្ថម្ភចំនួន ៤០ ០០០ រៀលក្នុង ១ដង ដែលផ្តល់ជាអតិបរមាចំនួន ១០ដង ក្នុងនោះ ៣ដង នៅពេលមកទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាលកូន និង ៧ដង នៅពេលយកកូនមកទទួលថ្នាំបង្ការរហូតដល់អាយុ ២ឆ្នាំ។

**មាត្រា៦.-**

ក្នុងករណីរលូតកូន ប្រាក់ឧបត្ថម្ភនេះ ត្រូវផ្តល់ដូចខាងក្រោម ÷

- ៤០ ០០០ រៀល តែ ១ដងគត់ ក្នុងករណីគភ៌អាយុក្រោម ១២សប្តាហ៍
- ៤០ ០០០ រៀល ក្នុង ១ដង ដែលផ្តល់ជាអតិបរមាចំនួន២ដង ក្នុងករណីគភ៌អាយុពី១២សប្តាហ៍ ដល់ ២៤សប្តាហ៍។

ក្នុងករណីរំលូតកូន ការឧបត្ថម្ភសាច់ប្រាក់ ត្រូវបញ្ឈប់ និងអ្នកទទួលផល ត្រូវចាកចេញពីកម្មវិធី។

ក្នុងករណីកូនស្លាប់ពេលសម្រាល ឬក្រោយពេលសម្រាល ប្រាក់ឧបត្ថម្ភ ត្រូវបន្តផ្តល់ ដូចខាងក្រោម ÷

- ២០០ ០០០ រៀល នៅពេលសម្រាល
- ៤០ ០០០ រៀលក្នុង ១ដង ដែលផ្តល់ជាអតិបរមាចំនួន ៣ដង នៅពេលមកទទួលសេវាពិនិត្យសុខភាព ក្រោយពេលសម្រាលកូន។

ក្នុងករណីម្តាយស្លាប់នៅពេលសម្រាល ប្រាក់ឧបត្ថម្ភ ត្រូវបន្តផ្តល់ជូនអាណាព្យាបាលស្របច្បាប់ ឬអ្នកដែលមានសិទ្ធិស្របច្បាប់ ឬអ្នកដែលនាំកូនមកទទួលសេវា ដូចខាងក្រោម ÷

- ២០០ ០០០ រៀល សម្រាប់ការសម្រាល
- ៤០ ០០០ រៀលក្នុង ១ដង ដែលផ្តល់ជាអតិបរមាចំនួន ១០ដង នៅពេលយកកូនមកទទួលសេវាថែទាំសុខភាពរហូតដល់កូនអាយុ២ឆ្នាំ។

**មាត្រា៧.-**

លក្ខខណ្ឌដើម្បីទទួលបានរបបគោលនយោបាយមានដូចខាងក្រោម ÷

- ស្ត្រីមានផ្ទៃពោះ ត្រូវមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព
- ស្ត្រីមានផ្ទៃពោះ បានពិនិត្យផ្ទៃពោះនៅមូលដ្ឋានសុខាភិបាលសាធារណៈយ៉ាងតិច ១ដង ដោយមានភ្ជាប់មកជាមួយនូវសៀវភៅសុខភាពមាតា ដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ
- កុមារដែលម្តាយ បានចុះឈ្មោះចូលក្នុងកម្មវិធីរួច កុមារនោះ ត្រូវបានចុះឈ្មោះជាស្វ័យប្រវត្តិ ដោយមានភ្ជាប់មកជាមួយនូវប័ណ្ណសុខភាពកុមារ
- កុមារដែលម្តាយ មិនបានចុះឈ្មោះក្នុងកម្មវិធី អាចចុះឈ្មោះបាន លុះត្រាតែមានប័ណ្ណសុខភាពកុមារ និងប័ណ្ណសមធម៌របស់គ្រួសារកុមារ។

## ជំពូកទី៣
## តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នដឹកនាំ ក្នុងការអនុវត្តកម្មវិធី

**មាត្រា៨.-**

ក្រុមប្រឹក្សាជាតិគាំពារសង្គម ទទួលបន្ទុកលើការងារក្របខណ្ឌគោលនយោបាយ ដូចខាងក្រោម ៖

- សម្របសម្រួលកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តកម្មវិធី
- ផ្ដល់ការតម្រង់ទិសផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងការអនុវត្តកម្មវិធី
- ពិនិត្យតាមដាន និងផ្ដល់យោបល់លើវឌ្ឍនភាពនៃការអនុវត្តកម្មវិធី
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជូនរាជរដ្ឋាភិបាល។

**មាត្រា៩.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធី ដែលមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រង និងការអនុវត្តកម្មវិធី
- ទទួលខុសត្រូវក្នុងការឧបត្ថម្ភសាច់ប្រាក់ជូនអ្នកទទួលផល ដែលជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារក្រីក្រ
- រៀបចំបង្កើតប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអប់រំផ្សព្វផ្សាយអំពីកម្មវិធី
- រៀបចំផែនការសកម្មភាព និងគម្រោងថវិកាសម្រាប់ការអនុវត្តកម្មវិធី
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន អង្គភាព និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ
- កៀរគរ និងគ្រប់គ្រងមូលនិធិដែលទទួលបានពីប្រភពផ្សេងៗសម្រាប់គាំទ្រការអនុវត្តកម្មវិធី
- តាមដាន វាយតម្លៃ និងរៀបចំរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តកម្មវិធី
- រៀបចំរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជូនក្រុមការងារបច្ចេកទេសអន្តរក្រសួង និងក្រុមប្រឹក្សាជាតិគាំពារសង្គម
- សហការពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហានានា ក្នុងការអនុវត្តកម្មវិធី។

**មាត្រា១០.-**

ក្រសួងមហាផ្ទៃ ជាស្ថាប័នទទួលបន្ទុកសម្របសម្រួល និងជួយគាំទ្រការអនុវត្តកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- រៀបចំ និងពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តតួនាទីរបស់អង្គភាពពាក់ព័ន្ធថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកម្មវិធី
- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងពាក់ព័ន្ធក្នុងការរៀបចំ និងផ្ដល់វគ្គបណ្ដុះបណ្ដាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងយន្តការដែលមានស្រាប់ នៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការពិនិត្យតាមដាន និងគាំទ្រការអនុវត្តកម្មវិធី
- សហការក្នុងការពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហានានា ក្នុងការអនុវត្តកម្មវិធី។

**មាត្រា១១.-**

ក្រសួងសុខាភិបាល មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំ និងពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធី តាមការចាំបាច់
- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងពាក់ព័ន្ធ ក្នុងការរៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាលពាក់ព័ន្ធការអនុវត្តកម្មវិធីដល់មូលដ្ឋានសុខាភិបាលសាធារណៈ
- ទទួលបន្ទុកផ្នែកបច្ចេកទេស ក្នុងការផ្តល់សេវាជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារក្រីក្រ
- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់ទិន្នន័យពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- បញ្ជាក់ការអនុវត្តលក្ខខណ្ឌជូនអ្នកទទួលផល ក្នុងការពិនិត្យផ្ទៃពោះមុនពេលសម្រាល នៅពេលសម្រាល ក្រោយពេលសម្រាល និងការផ្តល់ថ្នាំបង្ការដល់កុមារស្របតាមលក្ខណៈបច្ចេកទេសសុខាភិបាល និងតារាងពេលវេលា តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន និងផ្តល់បង្កាន់ដៃបញ្ជាក់ថាបានទទួលសេវារួចរាល់
- សហការពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធី។

**មាត្រា១២.-**

ក្រសួងផែនការ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- ផ្តល់ទិន្នន័យគ្រួសារក្រីក្រ ដែលមានសុពលភាពសម្រាប់ដាក់បញ្ចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដើម្បីបញ្ចូលទិន្នន័យគ្រួសារក្រីក្រទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- សម្របសម្រួល និងលើកកម្ពស់កិច្ចសហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីគាំទ្រការអនុវត្តកម្មវិធី
- ចូលរួមកសាងសមត្ថភាព ពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធី។

**មាត្រា១៣.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- ត្រួតពិនិត្យ ផ្តល់យោបល់ និងសម្រេចលើគម្រោងថវិកាសម្រាប់ការអនុវត្តកម្មវិធី
- វិភាជថវិកាសម្រាប់ការបើកផ្តល់របបឧបត្ថម្ភជូនអ្នកទទួលផល
- ពិនិត្យរបាយការណ៍សកម្មភាពការងារហិរញ្ញវត្ថុ និងសមិទ្ធកម្មរបស់កម្មវិធី
- ចូលរួមពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធី។

**មាត្រា១៤.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបង្កើតក្រុមការងារអន្តរក្រសួងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីសម្របសម្រួល អនុវត្ត និងពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តកម្មវិធី ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវចេញប្រកាសដាក់ឱ្យអនុវត្តសៀវភៅប្រតិបត្តិគោលស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារក្រីក្រ។

## ជំពូកទី៤

## ថវិកាអនុវត្តកម្មវិធី

**មាត្រា១៥.-**

រាល់ការចំណាយលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារក្រីក្រ ត្រូវហិរញ្ញប្បទានដោយថវិការដ្ឋ។

**មាត្រា១៦.-**

ការទូទាត់ចំណាយលើការឧបត្ថម្ភកម្មវិធីនេះក្នុង១វដ្តនៃការមានផ្ទៃពោះរហូតដល់កុមារអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារក្រីក្រ មិនត្រូវលើសពី ៧៦០ ០០០ រៀល។

## ជំពូកទី៥

## របាយការណ៍ និងការចុះពិនិត្យការអនុវត្តកម្មវិធី

**មាត្រា១៧.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំអំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជូនក្រុមប្រឹក្សាជាតិគាំពារសង្គម។ របាយការណ៍ប្រចាំត្រីមាសត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ។ របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ។

ក្នុងករណីចាំបាច់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវផ្តល់របាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី តាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា១៨.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្តីពីការអនុវត្តកម្មវិធីដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន និងត្រូវចម្លងជូនក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងត្រីមាសទី១ នៃឆ្នាំបន្ទាប់។

ការអនុវត្តកម្មវិធីនេះ ត្រូវស្ថិតនៅក្រោមអធិការកិច្ច និងសវនកម្មអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៩.-**

ក្រុមប្រឹក្សាជាតិគាំពារសង្គម មានសិទ្ធិចាត់តាំងមន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ចុះពិនិត្យ និងសង្កេតជាក់ស្តែងដល់ទីកន្លែង អំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនេះ។

## ជំពូកទី៦

## ការដោះស្រាយវិវាទ ឬបណ្តឹង

**មាត្រា២០.-**

មុនពេលប្តឹងទៅតុលាការ រាល់វិវាទ ឬបណ្តឹង ដែលមិនអាចផ្សះផ្សា ឬដោះស្រាយបានក្នុងកម្រិតក្រុមការងារប្រតិបត្តិកម្មវិធីនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ភាគីណាមួយនៃវិវាទ ឬបណ្តឹង អាចប្តឹងបន្តទៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមាននាយកដ្ឋាននីតិកម្ម ជាសេនាធិការទទួលបន្ទុកសម្របសម្រួល និងដោះស្រាយ។

**មាត្រា២១.-**

យន្តការ និងនីតិវិធីនៃការដោះស្រាយវិវាទ និងបណ្តឹងនៃការអនុវត្តកម្មវិធី ត្រូវកំណត់នៅក្នុងសៀវភៅប្រតិបត្តិ-គោលស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារក្រីក្រ។

## ជំពូកទី៧

## កាលបរិច្ឆេទនៃការអនុវត្ត

**មាត្រា២២.-**

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារក្រីក្រ ត្រូវបន្តអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ តទៅ។

## ជំពូកទី៨

## អន្តរប្បញ្ញត្តិ

**មាត្រា២៣.-**

អ្នកទទួលផលពីកម្មវិធី ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ៥២៤ សហវ.ប្រក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ នៃគ្រួសារមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព ត្រូវបន្តទទួលផលរហូតដល់ការអនុវត្តលក្ខខណ្ឌត្រូវបានបញ្ចប់។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៦ កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ